# សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

The Electoral Reform Alliance (ERA)

ភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៤

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ការផ្អាកដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៤**

នៅស្របពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចេញសេចក្តីសម្រេច ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៤ ដោយបានសម្រេចធ្វើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតសម្រាប់ឆ្នាំ២០១៤ ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) សូមស្នើឱ្យរដ្ឋសភាពិនិត្យលទ្ធភាពក្នុងការផ្អាកដំណើរនេះ។

ដោយយោងតាមការព្រមព្រៀងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ និងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤ ក្នុងការរៀបចំការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត ព្រមទាំងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរវាងគណបក្សទាំងពីរចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ ត្រង់ប្រការ ២ វាក្យខ័ណ្ឌទី២ បានព្រមព្រៀង "រៀបចំបញ្ជីឈ្មោះបោះឆ្នោតជាថ្មី"។

ដោយពិនិត្យឃើញឆន្ទៈនយោបាយរបស់គណបក្សដែលទទួលបានអាសនៈក្នុងរដ្ឋសភា នីតិកាលទី៥នេះ ព្រមព្រៀងបង្កើត"បញ្ជីបោះឆ្នោតថ្មីមួយ" ដើម្បីធានាសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋគ្រប់រូប។ ម្យ៉ាងវិញទៀត ដើម្បីកុំឱ្យចំណាយថវិកាជាតិ ព្រោះថាចំណាយក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំដែលមិនមានការបោះឆ្នោត ប្រមាណជាងមួយ(១)លានដុល្លារសហរដ្ឋអាមេរិក។

ដូច្នេះសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) សូមស្នើឱ្យរដ្ឋសភាលើកសំណើទៅ គ.ជ.ប ដើម្បីផ្អាកដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតសម្រាប់ ឆ្នាំ២០១៤នេះ រហូតដល់មានច្បាប់បទបញ្ញា និងនីតិវិធីចុះឈ្មោះបោះឆ្នោត និងការបង្កើតបញ្ជីឈ្មោះបោះឆ្នោតថ្មីត្រូវបានប្រកាសឱ្យប្រើប្រាស់។

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) សូមអំពាវនាវឱ្យក្រុមការងារគណៈកម្មការចម្រុះនៃគណបក្សទាំងពីរ បន្តពិភាក្សាលើវិសោធនកម្មច្បាប់បោះឆ្នោត ជាពិសេសជំពូកស្តីពីការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ដោយផ្តោតសំខាន់លើការប្តូរមន្ត្រីទទួលបន្ទុកការពិនិត្យឈ្មោះ និងចុះឈ្មោះបោះ

ឆ្នោត ដោយកំណត់ឱ្យ គ.ជ.ប ជាស្ថាប័នតែមួយជំនួសក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ទទួលខុសត្រូវធ្វើការចុះឈ្មោះអ្នកបោះឆ្នោតថ្មីមួយ ដើម្បីធានាគុណភាពបញ្ជីឈ្មោះបោះឆ្នោត និងសិទ្ធិអ្នកបោះឆ្នោត។

**សម្រាប់ព័ត៌មានបន្ថែម៖**

| | **ឈ្មោះ** | **អង្គការ** | **លេខទូរស័ព្ទ** |
|---|---|---|---|
| • | លោក នី ចរិយា | អាដហុក | ០១១ ២៧៤ ៩៥៩ |
| • | លោក ព្រាប កុល | តម្លាភាពកម្ពុជា | ០១២ ៨៧៧ ៨៣៣ |
| • | លោក ហង្ស ពុទ្ធា | និកហ្វិច | ០១២ ៩៥៩ ៦៦៦ |
| • | លោក យង់ គិមអេង | ភីដីភី សិនធ័រ | ០១៦៨២៨ ២១១ |
| • | លោក គល់ បញ្ញា | ខុមហ្វ្រែល | ០១២ ៩៤២ ០១៧ |
| • | លោក សុខ ពិទូរ្យ | វាយ ស៊ី ស៊ី | ០១៧ ២៧៣ ៣០៣ |
| • | លោក គាន ពន្លក | ដ្រាក | ០១២ ៥៥១ ៤៦៦ |
| • | លោក ហ៊ឹម យន់ | សម្ព័ន្ធស៊ីសា | ០១២ ៩៤៧ ០២២ |
| • | លោក យ៉េង វិរៈ | ខ្លែក | ០១២ ៨០១ ២៣៥ |